00760181

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/N°: ៣

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៣/២៩-០៧-២០១១-អវតក/(អបជ ០១)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 12 / 2011
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ (សំណៅកោសល្យ)**

## សេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឲ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣

**សហចៅក្រមស៊ើបអង្កេត**
លោក យូ ប៊ុនឡេង
លោក Siegfried BLUNK

**សហព្រះរាជអាជ្ញា**
អ្នកស្រី ជា លាង
Andrew CAYLEY

**អ្នកស្នើសុំ**
Ms. Nisha VALABHJI
មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
សំ សុគង់
Lyma Thuy NGYEN
CHOUNG Chou-Ngy

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “សំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឱ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣” (“សំណើ”) ដែលបានដាក់ដោយមន្ត្រីទទួលបន្ទុក (“អ្នកស្នើសុំ”) ក្នុងអង្គភាពគាំពារការការពារក្តី (DSS) នៃអ.វ.ត.ក នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១[១]។

២. នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ អ្នកស្នើសុំបានដាក់សេចក្តីបន្ថែមចំពោះសំណើ (“សេចក្តីបន្ថែមទីមួយ”)[២]។ នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១១ អ្នកស្នើសុំបានដាក់សេចក្តីបន្ថែមទីពីរចំពោះសំណើ (“សេចក្តីបន្ថែមទីពីរ”)[៣]។ នៅក្នុងសេចក្តីបន្ថែមទាំងពីរចំពោះសំណើ អង្គភាពគាំពារការការពារក្តីផ្តល់ព័ត៌មាន បន្ថែមពាក់ព័ន្ធនឹងការវិវត្តនៃ [redacted]។ ពុំទាន់មានចម្លើយតបណាមួយចំពោះសំណើនេះនៅឡើយទេ។

**សំណូមពរៈ**

៣. សំណើនេះមានសំណូមពរដូចខាងក្រោម៖

“ក. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី សូមស្នើឱ្យអង្គបុរេជំនុំជម្រះផ្អាកដំណើរការនីតិវិធី នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដើម្បីឱ្យអង្គភាពនេះ ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីផ្តល់ការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាពដល់ជនសង្ស័យក្នុងសំណុំរឿង

[១] សំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឱ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣, ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ 1 (“សំណើ”)។

[២] សេចក្តីបន្ថែមចំពោះសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅចំពោះអង្គបុរេជំនុំជម្រះ និងសុំឱ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣, ឯកសារលេខ 1/1, ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១។

[៣] សេចក្តីបន្ថែមទីពីរចំពោះសំណើសុំផ្អាកដំណើរការនីតិវិធី នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឱ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធភាពជូនជនសង្ស័យក្នុងសំណុំរឿង ០០៣ ឯកសារ លេខ ២.១ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១។



អង្គបុរេជំនុំជម្រះ E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

០០៣ សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងបញ្ហាដទៃទៀតដែលអង្គបុរេជំនុំជម្រះចាត់ទុកថាសមស្រប។

ខ. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី សូមស្នើឱ្យអង្គបុរេជំនុំជម្រះបង្គាប់ឱ្យការិយាល័យរដ្ឋបាលផ្ដល់ជំនួយផ្នែកសម្ភារៈ ហិរញ្ញវត្ថុ និងរដ្ឋបាលដល់អង្គភាពគាំពារការការពារក្ដីដែលត្រូវការជាចាំបាច់ដើម្បីទំនាក់ទំនងជនសង្ស័យ និងបង្ហាញពួកគេនូវបញ្ជីឈ្មោះមេធាវីការពារក្ដី ដូចដែលមានចែងក្នុងវិធាន ១១(២) (ង) នៃវិធានផ្ទៃក្នុង សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងបញ្ហាដទៃទៀតដែលអង្គបុរេជំនុំជម្រះចាត់ទុកថាសមស្រប។

គ. ក្នុងរយៈពេលបណ្ដោះអាសន្ននេះ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី សូមស្នើឱ្យអង្គបុរេជំនុំជម្រះ ចេញដីកាបង្គាប់ឱ្យអនុប្រធានការិយាល័យរដ្ឋបាលដោយបង្គំ [redacted] និង

ឃ. អនុលោមតាមកម្មវត្ថុនៃតម្លាភាព និងការយល់ដឹងរបស់សាធារណជនអំពីដំណើរការយុត្តិធម៌ អង្គភាពគាំពារការការពារក្ដីសូមស្នើឱ្យចាត់ចំណាត់ថ្នាក់ញត្តិនេះជាឯកសារ "សាធារណៈ" នៅពេលការកោសលុបចាំបាច់ត្រូវបានធ្វើឡើង"[៤]។

**មូលដ្ឋាននៃសំណើ:**

៤. ដូចដែលបានដកស្រង់ខាងលើរួចហើយ យុត្តិកម្មចំពោះ "ការផ្អាកដំណើរការនីតិវិធីនៅ អ.ប.ជ" គឺដើម្បី "ឱ្យអង្គភាពនេះ ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីផ្ដល់ការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាពដល់ជនសង្ស័យក្នុងសំណុំរឿង ០០៣ សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខ អ.ប.ជ"[៥]។ សំណើនេះក៏បានលើកឡើងដែរថា៖

"ដំណើរការនីតិវិធីផ្សេងៗនៅចំពោះមុខអង្គបុរេជំនុំជម្រះដែលមានចែងក្នុងផ្នែក ២.២ នៃញត្តិនេះតម្រូវឱ្យមានការចូលរួមពីមេធាវីការពារក្ដី ព្រោះជនសង្ស័យមានសិទ្ធិទទួលសិទ្ធិជាមូលដ្ឋានទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព។

[៤] សំណើ, កថាខណ្ឌ ៧១។

[៥] សំណើ, កថាខណ្ឌ ៧១(ក)។

ការបន្តដំណើរការនីតិវិធីទាំងនេះដោយគ្មានការចូលរួមពីមេធាវីការពារក្តី នឹងរំលោភបំពានលើផ្នែកជាច្រើននៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយតតាំងក្តី សិទ្ធិទទួលបានការតំណាងប្រកបដោយប្រសិទ្ធភាព និងសិទ្ធិទទួលបានការគោរពគោលការណ៍ចំពោះមុខដែលមានចែងក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង។

ដូច្នេះ ដំណើរការនីតិវិធី ត្រូវតែផ្អាកដើម្បីឱ្យអង្គភាពគាំពារការការពារក្តី ដោយមានការគាំទ្រពីការិយាល័យរដ្ឋបាល និងអង្គភាពពាក់ព័ន្ធទាំងអស់ ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីធានាសិទ្ធិជាមូលដ្ឋានរបស់ជនសង្ស័យទទួលបានការតំណាងផ្នែកច្បាប់ សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងបញ្ហាដទៃទៀតដែលអង្គបុរេជំនុំជម្រះចាត់ទុកថាសមស្រប”[៦]។

## ភាពអាចទទួលយកបាននៃសំណើ:

៥. សំណើនេះមិនបានលើកឡើងថា តើសំណើនេះស្ថិតក្រោមយុត្តាធិការរបស់អង្គបុរេជំនុំជម្រះក្នុងការសម្រេចសេចក្តី ឬយ៉ាងណានោះទេ។

៦. អនុលោមតាមវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះមានយុត្តាធិការច្បាស់លាស់ទៅលើ៖ ការដោះស្រាយករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា[៧] ការដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត[៨] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដូចមានចែងនៅក្នុងវិធាន ៧៤[៩] ពាក្យសុំមោឃភាពនៃកិច្ចស៊ើបសួរណាមួយ ដូចមានចែងនៅក្នុងវិធាន ៧៦[១០] និងបណ្តឹងឧទ្ធរណ៍ផ្សេងៗទៀត ដែលមានចែងនៅក្នុងវិធាន ១១(៥) និង (៦) និង វិធាន ៣៥

---

[៦] សំណើ, កថាខណ្ឌ ៦៨-៧០។

[៧] វិធាន ៧១ នៃវិធានផ្ទៃក្នុង។

[៨] វិធាន ៧១ នៃវិធានផ្ទៃក្នុង។

[៩] វិធាន ៧៣(ក) និង ៧៤ នៃវិធានផ្ទៃក្នុង។

[១០] វិធាន ៧៣(ខ) និង ៧៦ នៃវិធានផ្ទៃក្នុង។

(៦) វិធាន ៣៨(៣) និង វិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុងនេះ[១១]។ សំណើរបស់អង្គភាពគាំពារការការពារក្តីមិនបានយោង ឬមិនស្ថិតនៅក្នុងបទប្បញ្ញត្តិណាមួយក្នុងចំណោមបទប្បញ្ញត្តិទាំងនេះទេ។

៧. ទោះជាយ៉ាងណាក្តី សំណើនេះបានលើកជាទឡ្ហីករណ៍ថា ការបន្តដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ដោយពុំមានការចូលរួមពី "មេធាវីការពារក្តី"[១២] នឹងរំលោភបំពានលើផ្នែកជាច្រើននៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយតតាំងក្តី សិទ្ធិទទួលបានការតំណាងប្រកបដោយប្រសិទ្ធភាព និងការតទល់គ្នានៅក្នុងដំណើរការនីតិវិធី។

៨. អ.ប.ជ ធ្លាប់បានយកមកប្រើពីមុនរួចមកហើយនូវយុត្តាធិការជាមូលដ្ឋានរបស់ខ្លួន ដើម្បីទទួលយកបណ្តឹងឧទ្ធរណ៍ដែលទាក់ទិននឹងសំណើសុំផ្អាកដំណើរការនីតិវិធី និងនៅក្នុងកាលៈទេសៈពិសេសដែលតម្រូវឱ្យធ្វើបែបនេះ។ អ.ប.ជ ក៏បានពិនិត្យឡើងវិញជាថ្មីនូវសំណើទាំងនោះ នៅពេលដែលបញ្ហានៃភាពយុត្តិធម៌នៃដំណើរការនីតិវិធីត្រូវបានលើកឡើងចំពោះមុខអង្គបុរេជំនុំជម្រះ[១៣]។ ការប្រើប្រាស់យុត្តាធិការជាមូលដ្ឋានរបស់ខ្លួននេះ គឺស្របទៅនឹងការអនុវត្តនៅចំពោះមុខតុលាការអន្តរជាតិ ឬតុលាការដែលមានលក្ខណៈជាអន្តរជាតិដទៃទៀតដែរ៖

> "អនុលោមតាមច្បាប់យុត្តិសាស្ត្រដែលបានបង្កើតឡើងពីតុលាការយុត្តិធម៌អន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការអន្តរជាតិដទៃទៀត តុលាការអន្តរជាតិមួយអាចសម្រេចទៅលើបញ្ហានានាដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងតុលាការនោះ បើតាមន័យចង្អៀត ទោះបីមិនស្ថិតនៅក្នុង "យុត្តាធិការដើម" របស់តុលាការនោះក៏ដោយ ហើយគេត្រូវពិនិត្យទៅលើផលប្រយោជន៍នៃភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងកិច្ចការរដ្ឋបាលរបស់តុលាការដែរ។ និយាយម្យ៉ាងទៀត ក្នុងការអនុវត្តមុខងាររបស់ខ្លួន តុលាការនោះមានយុត្តាធិការដោយប្រយោល ក្នុងការសម្រេចទៅលើបញ្ហានានាដែលកើតឡើងមាន

[១១] វិធាន ៧៣(គ) នៃវិធានផ្ទៃក្នុង។

[១២] ការគូសបញ្ជាក់បន្ថែមត្រូវបានធ្វើឡើងទៅលើពាក្យដែលមានបញ្ចូលក្នុងអត្ថន្តរសញ្ញា។ ការពន្យល់ចំពោះការគូសបញ្ជាក់បន្ថែមនៅក្នុងកថាខណ្ឌនានាដែលមានជាបន្តបន្ទាប់។

[១៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០, ឯកសារលេខ D264/2/6, កថាខណ្ឌ ១០ និង ១៧-១៨។

PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

ទំនាក់ទំនងទៅនឹងអាណត្តិការងាររបស់ខ្លួន ឬមានផលប៉ះពាល់ចំពោះខ្លួន និងដែលត្រូវតែយកមកដោះស្រាយដើម្បីជាប្រយោជន៍ផ្នែកយុត្តិធម៌”[១៤]។

៩. អង្គបុរេជំនុំជម្រះអាចប្រើប្រាស់យុត្តាធិការជាមូលដ្ឋានរបស់ខ្លួនបានទៅតាមករណីជាក់ស្តែង ប្រសិនបើបណ្តឹងឧទ្ធរណ៍ណាមួយ ឬសំណើពាក់ព័ន្ធណាមួយមិនត្រឹមតែទាក់ទិននឹងបញ្ហាជាសារវ័ន្តប៉ុណ្ណោះទេ តែថែមទាំងត្រូវបានលើកឡើងយ៉ាងសមរម្យផងដែរ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងផ្នែកសំណូមពរ សំណើបានយោងជាសំខាន់ទៅដល់ “មេធាវីការពារក្តី” ក៏ប៉ុន្តែ តាមលក្ខណៈនៃសិទ្ធិ គេយល់ថា ចំណុចសំខាន់នៃទឡ្ហីករណ៍នៅក្នុងសំណើនេះ គឺផ្អែកលើសិទ្ធិមានតំណាងតាមផ្លូវច្បាប់សម្រាប់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ០០៤ មិនមែនសិទ្ធិណាមួយរបស់មេធាវីទេ។ ចំណុចផ្សេងទៀតនៃសំណូមពរ អាស្រ័យទៅលើដំណោះស្រាយចំពោះបញ្ហាសិទ្ធិរបស់ជនសង្ស័យនេះឯង។

១០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ទាក់ទិននឹងសិទ្ធិមានតំណាងតាមផ្លូវច្បាប់ កាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានផ្តល់នូវការបញ្ជាក់ដល់អង្គភាពគាំពារការការពារក្តីដូចខាងក្រោម៖

> “សិទ្ធិរបស់ចុងចោទត្រូវតែអនុវត្តឱ្យបានពេញលេញ (ហើយគោលការណ៍នៃសមភាពនៃមធ្យោបាយតតាំងក្តីត្រូវតែតម្កល់ជាដាច់ខាត) *នៅពេលដែលជនម្នាក់ត្រូវបានចោទប្រកាន់ទោស* ហើយក្លាយជាភាគីមួយនៃកិច្ចដំណើរការនីតិវិធី។ ទោះជាយ៉ាងណាក្តី ដរាបណាជនណាម្នាក់មិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការទេនោះ សិទ្ធិរបស់ជននោះនៅមានកម្រិត។ ករណីនេះគេអនុវត្តនៅគ្រប់ប្រព័ន្ធនីតិវិធីទាំងអស់។
>
> នៅក្នុងឧទាហរណ៍នេះ វិធានផ្ទៃក្នុងបានបញ្ជាក់ច្បាស់ពីសិទ្ធិរបស់ជនសង្ស័យ ឧទាហរណ៍នៅពេលជនទាំងនោះត្រូវបានហៅថាជាសាក្សី (វិធាន ២៤-៤ និង ២៨) ត្រូវបានឃាត់ខ្លួនដោយនគរបាលយុត្តិធម៌ (វិធាន ៥១) ឬត្រូវបានឆែកឆេរ (វិធាន ៦១)។ នៅក្នុងឧទាហរណ៍ទាំងនេះ “ជនសង្ស័យដែលមិនបញ្ចេញឈ្មោះ” ដែលលោកចៅក្រមបានយោងនោះ ទទួលបានសិទ្ធិនានាដែលបានលើកឡើងនោះយ៉ាងពេញលេញ។ ទោះជា

[១៤] សេចក្តីសម្រេចទាក់ទិននឹងយុត្តាធិការរបស់តុលាការ ដើម្បីសម្រេចទៅលើពាក្យសុំរបស់លោក El Sayed ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០១០ និងសម្រេចថាតើ លោក El Sayed មានតួនាទីនៅចំពោះមុខតុលាការឬទេ, តុលាការ STL, ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១០, សំណុំរឿងលេខ CH/PTJ/2010/005, កថាខណ្ឌ ៣១ (ជើងទំព័រត្រូវបានលុបចោល)។

យ៉ាងណាក្ដី ជនសង្ស័យទាំងនោះមិនអាចទាមទារសិទ្ធិជាភាគីក្នុងកិច្ចដំណើរការនីតិវិធី ដូចមានចែងក្នុងចំណោមនោះមាន វិធាន ៥៥(៨), ៥៥(១០), ៥៥(១១), ៥៧ និង ៥៨ បានទេ ដោយសារនៅក្នុងចំណុចនេះពុំមាននរណាម្នាក់អាចព្យាករណ៍ដឹងជាមុនបានពីលទ្ធផលនៃកិច្ចស៊ើបសួរទេ។

ក្នុងន័យនេះ គេគួររំលឹកឡើងវិញដល់ពាក្យពេចន៍នៅក្នុងដីកាបញ្ជាក់របស់យើង (ដែលបានចេញផ្សាយជាសាធារណៈ) ដែលបានកំណត់ច្បាស់ពីផលវិបាកនៃវិសាលភាពនៃកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតគឺថា៖ កាតព្វកិច្ចក្នុងការស៊ើបសួរគ្រប់អង្គហេតុទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតត្រូវធ្វើ មិនត្រូវច្រឡំជាមួយនឹង "កាតព្វកិច្ចក្នុងការចោទប្រកាន់" ដែលពាក់ព័ន្ធនឹងអង្គហេតុនោះទេ (...) វាកើតចេញពីពាក្យពេចន៍ដែលមានចែងក្នុងវិធាន ៥៥(៤)៥ តែម្ដងដែលថា សហចៅក្រមស៊ើបអង្កេតមាន "អំណាច" តែមិនមានកាតព្វកិច្ច ក្នុងការចោទប្រកាន់ជនណាម្នាក់ ទោះបីជននោះមានឈ្មោះ ឬពុំមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ។

នៅពេលសហចៅក្រមស៊ើបអង្កេតសម្រេចចោទប្រកាន់ជនណាម្នាក់ សហចៅក្រមស៊ើបអង្កេតមានសេរីភាពក្នុងការជ្រើសរើសថាតើគួរធ្វើការចោទប្រកាន់ពេលណាមួយបាន។ យ៉ាងណាក៏ដោយ "អំណាច" ក្នុងការចោទប្រកាន់មានចែងនៅក្នុងបទប្បញ្ញត្តិនៃវិធាន ២៤(៤) ផង ដែលប្រកាសកោះហៅក្នុងនាមជាសាក្សីចំពោះជនណាម្នាក់ដែលមានភស្តុតាងបង្ហាញពីការទទួលខុសត្រូវព្រហ្មទណ្ឌប្រឆាំងនឹងខ្លួន និង វិធាន ៥៥(៤) ដែលថាការចោទប្រកាន់អាចនឹងធ្វើបានលុះត្រាតែមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាដែលបង្ហាញថា ជនណាម្នាក់អាចនឹងទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ ក.ស.ព ទោះបីជននោះមានឈ្មោះ ឬមិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះក៏ដោយ"[១៥]។

១១. អង្គបុរេជំនុំជម្រះកត់សម្គាល់ ដូចដែលអ្នកស្នើសុំបានធ្វើការសង្កេតដោយត្រឹមត្រូវផងដែរ[១៦] ថា ការបញ្ជាក់របស់សហចៅក្រមស៊ើបអង្កេតដែលបានដកស្រង់ខាងលើ មិនមានន័យថាជាការបដិសេធនូវ

---

[១៥] លិខិតពីសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវីការពារក្ដីដែលមានចំណងជើងថា "សិទ្ធិរបស់មេធាវីក្នុងការចូលទៅក្នុងសំណុំរឿង ០០៣ និង ០០៤" ឯកសារលេខ D3.1.31 (A1/2), ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០។

[១៦] សំណើ, កថាខណ្ឌទី ២០។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

សំណើដែលពាក់ព័ន្ធនោះទេ។ ផ្ទុយទៅវិញ បើតាមច្បាប់ជាធរមាន ការបញ្ជាក់នេះបានពន្យល់ថា សិទ្ធិមានការតំណាងមាននៅពេលដែលជនណាម្នាក់ត្រូវបាននាំខ្លួនមកចំពោះមុខចៅក្រម ឬ *"ត្រូវបានចោទប្រកាន់"*។ អង្គបុរេជំនុំជម្រះយល់ស្របថា ពេលវេលានៃសិទ្ធិមានការតំណាងវាអាស្រ័យទៅនឹងដំណើរការនៃការស៊ើបអង្កេតនោះ។ នេះជាបញ្ហាដែលស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដោយសារគាត់ទទួលបន្ទុកស៊ើបអង្កេត។ ដូចដែលបានពន្យល់ដោយ សហចៅក្រមស៊ើបអង្កេតរួចមកហើយ នៅកម្ពុជា ស្រដៀងគ្នានឹងបណ្តាប្រព័ន្ធនីតិវិធីច្បាប់ជាតិ និងតុលាការអន្តរជាតិជាច្រើនទៀតដែរ ស្ថាប័នដែលមានអំណាចក្នុងការស៊ើបអង្កេតមានកាតព្វកិច្ចក្នុងការធ្វើឱ្យប្រាកដថា នៅពេលដែលជនណាម្នាក់*ត្រូវបាននាំខ្លួនមកចំពោះមុខខ្លួន*ហើយនោះ មុននឹងសាកសួរយកចម្លើយ ជននោះនឹងត្រូវបានទទួលព័ត៌មានជាភាសាដែលខ្លួនយល់បាន[១៧] ហើយក្នុងចំណោមសិទ្ធិដទៃទៀត ជននោះមានសិទ្ធិមានមេធាវីការពារទៅតាមការជ្រើសរើសរបស់ខ្លួន ឬទទួលមេធាវីជំនួយផ្នែកច្បាប់ដែលត្រូវបានចាត់តាំងដោយមិនគិតថ្លៃ ប្រសិនបើជនសង្ស័យពុំមានមធ្យោ-បាយក្នុងការបង់ថ្លៃសេវាមេធាវីទេនោះ[១៨]។ ចំណុចនេះមានន័យថា សិទ្ធិមានតំណាងតាមផ្លូវច្បាប់គឺសិទ្ធិ*ផ្ទាល់*របស់ជនសង្ស័យក្នុងការជ្រើសរើសយកសិទ្ធិនោះមកអនុវត្ត ឬមិនអនុវត្តទៅតាម*ឆន្ទៈដោយសេរី* របស់ខ្លួនទេ។ សិទ្ធិនេះមិនមែនសម្រាប់ឱ្យអ្នកដទៃណាម្នាក់សម្រេចក្នុងនាមជនសង្ស័យទេ។ ជនសង្ស័យអាចជ្រើសរើសការពារខ្លួនដោយខ្លួនឯងបាន។ ប្រសិនបើជនសង្ស័យផ្តល់ព័ត៌មានទៅចៅក្រម ឬអង្គជំនុំជម្រះដែលខ្លួនត្រូវបង្ហាញខ្លួននោះថា ខ្លួនបានទាក់ទងមេធាវីរួចហើយ ពេលនោះខ្លួនត្រូវដាក់លិខិតប្រគល់សិទ្ធិដោយអាណត្តិទៅផ្នែករដ្ឋបាល (Registry) ហើយប្រសិនបើមេធាវីនោះ

---

[១៧] មាត្រា ១៤(៣) (ក) និង (ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និង មាត្រា ៦(៣)(ក) *(សិទ្ធិទទួលបានការជូនដំណឹង)* (ខ)*(សិទ្ធិការការពារខ្លួន)* និង (គ)*(សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ សិទ្ធិមានជំនួយផ្នែកច្បាប់)* នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR)។ *រឿងក្តី Ofner តទល់នឹង ប្រទេសអូទ្រីស,* សំណុំរឿងលេខ 524/59, 3 YB 322 ត្រង់ 344 (ឆ្នាំ ១៩៦០)៖ មានការត្រួតគ្នារវាងមាត្រា ៦(៣)(ក) និង មាត្រា ៦(៣)(ខ) ការស្របតាមបញ្ញត្តិទីមួយ ជាលក្ខខណ្ឌចាំបាច់ដែលត្រូវស្របតាមបញ្ញត្តិទីពីរ"។ *Accord* Harris, M O'Boyle & C Warbrick, ច្បាប់នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, OXFORD University Press, ការបោះពុម្ពលើកទី១ ឆ្នាំ ១៩៩៥, ទំព័រ ២៥០ ("សេចក្តីអធិប្បាយទី១ នៃ ECHR")។

[១៨] វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ មាត្រា ៥៥(២)(គ) នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) និង វិធាន ៤២(ក)(១) នៃវិធាននីតិវិធី និងភ័ស្តុតាង (RPE) នៃតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ដែលអនុវត្តនៅក្នុងដំណាក់កាលដូចគ្នានៃកិច្ចដំណើរការនីតិវិធីនៅតុលាការ ICTY ក៏ដូចគ្នានឹងដំណាក់កាលនៃដំណើរការនីតិវិធីនៃក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននៅ អ.វ.ត.ក ដែរ។



ECCC * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

បានបំពេញតាមលក្ខខណ្ឌកំណត់នោះ គាត់មានសិទ្ធិបំពេញការងារក្នុងនាមជនសង្ស័យបាន[១៩]។ ជនសង្ស័យដែលទីទ័លក្រ ត្រូវទទួលបានមេធាវីដែលគេចាត់តាំង[២០] ដោយសារ "ផលប្រយោជន៍ផ្នែកយុត្តិធម៌តម្រូវបែបនេះ"[២១]។ ទោះបីសេចក្តីណែនាំក្នុងការចាត់តាំងមេធាវីត្រូវបានរៀបចំដោយប្រធានរដ្ឋបាល (Registrar) ក៏ដោយ តែសេចក្តីណែនាំទាំងនោះត្រូវតែ*អនុម័តដោយចៅក្រម*[២២]។ "ប្រសិនបើ [ចៅក្រម]សម្រេចថា វាជាប្រយោជន៍ផ្នែកយុត្តិធម៌" ចៅក្រមអាច *ណែនាំឲ្យប្រធានរដ្ឋបាល (Registrar )តែងតាំងមេធាវីម្នាក់* ដើម្បីតំណាងផលប្រយោជន៍របស់ជនជាប់ចោទ[២៣]។ តួនាទី និងមុខងាររបស់ប្រធានរដ្ឋបាល (Registrar) នៅតុលាការ ICTY ស្រដៀងគ្នានឹងតួនាទី និងមុខងាររបស់ប្រធាន/អនុប្រធានរដ្ឋបាលនៅ អ.វ.ត.ក ដែរ ពោលគឺមន្ត្រីទាំងនេះជួយអង្គជំនុំជម្រះ "បំពេញបេសកកម្មការងាររបស់ខ្លួន"[២៤]។

១២. អង្គបុរេជំនុំជម្រះសង្កេតបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតមិនបានសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្នដល់ជនដែលមានឈ្មោះ

---

[១៩] សូមមើលផងដែរ វិធាន ៤៤ នៃ RPE នៃតុលាការ ICTY ស្រដៀងនឹងវិធាន ២២(១)(ក) នៃវិធានផ្ទៃក្នុងដែរ។

[២០] វិធាន ២២(១)(ខ) នៃវិធានផ្ទៃក្នុង។

[២១] សូមមើលផងដែរ មាត្រា ៥៥(២)(គ) នៃលក្ខន្តិកៈតុលាការ ICC និងវិធាន ៤៥(ក) នៃ RPE នៃតុលាការ ICTY ។

[២២] សូមមើលវិធាន ១១(២)(ក) នៃវិធានផ្ទៃក្នុង រួមជាមួយនឹងវិធាន ៤ និង វិធាន ២០ នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ វិធាន ៤៥ នៃ RPE នៃតុលាការ ICTY។

[២៣] វិធាន ៤៥*ស្ទួនពីរ* នៃ RPE នៃតុលាការ ICTY។

[២៤] សូមមើលផ្នែកទី III នៃវិធាននីតិវិធី និងភ័ស្តុតាង នៅតុលាការ ICC និងជាពិសេសគឺវិធាន ១៣, ១៤, ១៥, ២០, ២១ និង ២២ រួមជាមួយមាត្រា ៥៥(២)(គ) នៃលក្ខន្តិកៈតុលាការ ICC។ សូមមើលផងដែរ វិធាន ៣៣ស្ទួន(ខ)(១) នៃតុលាការ ICC ប្រៀបធៀបទៅនឹងវិធាន ៩(១), ១០(២) និង ១១ នៃវិធានផ្ទៃក្នុង។ គួរបញ្ជាក់បន្ថែមត្រូវបានធ្វើឡើង ដោយសារថា វិធាន ១១ នៃវិធានផ្ទៃក្នុង គឺជាផ្នែកមួយនៃផ្នែក ខ នៃវិធានផ្ទៃក្នុងដែលមានចំណងជើងថា៖ "ការិយាល័យរដ្ឋបាល"។ DSS គឺជាផ្នែកមួយនៃ DOA/DDOA ដែលបំពេញការងារតែទៅតាមស្វ័យភាពដែលកំហិតដោយ DOA/DDOA ដូចមានចែងក្នុងវិធាន ១១ នៃវិធានផ្ទៃក្នុង ហើយមុខងាររបស់វាត្រូវបានបង្កើតឡើងនៅពេលដែលស្វ័យភាពទទួលបន្ទុកកិច្ចដំណើរការនីតិវិធីដែលកំពុងបន្តផ្តល់ការណែនាំដល់ DSS តាមរយៈ DOA/DDOA ឬ នៅពេលកាលៈទេសៈពិសេសតម្រូវឲ្យផ្តល់ស្វ័យភាពដោយផ្ទាល់ដល់ DSS តែប៉ុណ្ណោះ។

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

00760190



នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤[២៥] ទេ។ សហព្រះរាជអាជ្ញាអន្តរជាតិក៏ពុំបានប្តឹងឧទ្ធរណ៍ទាក់ទិននឹងការដែលសហចៅក្រមស៊ើបអង្កេតមិនបានសម្រេចទៅសំណើទាំងនេះដែរ។

១៣. នៅពេលដែលសំណើត្រូវបានដាក់ជូនទៅអង្គបុរេជំនុំជម្រះ និងនៅពេលថ្មីៗនេះ ដំណើរការនីតិវិធីព្រហ្មទណ្ឌនៅក្នុងសំណុំរឿង ០០៣ និង ០០៤ មកដល់ដំណាក់កាលមួយដែល "សេចក្តីជូនដំណឹងពីការសន្និដ្ឋានបញ្ចប់កិច្ចស៊ើបសួរ" ត្រូវបានចេញនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ហើយការស៊ើបអង្កេតកំពុងដំណើរការនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅឡើយ។ ដោយសារសហចៅក្រមស៊ើបអង្កេតជាអ្នកបានទទួល និងទទួលបន្ទុកស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលកំពុងបន្តនោះ បញ្ហានៃការតំណាងតាមផ្លូវច្បាប់គឺស្ថិតក្នុងការសម្រេចដោយផ្ទាល់របស់សហចៅក្រមស៊ើបអង្កេត ហើយហេតុនេះវាពុំស្ថិតនៅក្នុងយុត្តាធិការរបស់ អ.ប.ជ ទេ។ ការដែលថាមានដីកាសម្រេចខ្លះរបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានប្តឹងឧទ្ធរណ៍មកអង្គបុរេជំនុំជម្រះ ពុំបានផ្លាស់ប្តូរសំអាងហេតុនេះទេ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា៖**

សំណើនេះមិនអាចទទួលយកបានទេ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១១

ចៅក្រមអង្គបុរេជំនុំជម្រះ

ប្រធាន

**Rowan DOWNING** **នំយ ថុល** **Katinka LAHUIS** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

---

[២៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារលេខ D1, កថាខណ្ឌ ១០២។ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩, ឯកសារលេខ D1/1, កថាខណ្ឌ ៩។